ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

# ដីកាសម្រេចអំពីការបន្តថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

# Order on Extension of Provisional Detention

# Ordonnance sur la prolongation de la détention provisoire

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្ដីពី អ.វ.ត.ក.")

បានឃើញវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **អៀង ធីរិទ្ធ**
ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះ **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្ដន្ទាទោស តាមមាត្រា៥ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

បានឃើញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន អៀង ធីរិទ្ធ ក្នុងរយៈពេលអតិបរមាមួយឆ្នាំ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ (C20)

បានឃើញសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះឆ្លើយតបចំពោះបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៨ (C20/I/26)

បានឃើញសេចក្ដីជូនដំណឹងចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៨ ដែលក្នុងនោះយើងបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ខ្លួន អំពីគោលបំណងរបស់យើងក្នុងការបន្តថេរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ដែលនឹងត្រូវផុតរលត់នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ហើយនិងបានឲ្យជាដំណឹងដល់ពួកគេថា ពួកគេមានរយៈពេល ១៥ ថ្ងៃ ដើម្បីធ្វើការកត់សម្គាល់ ឬតវ៉ាមកយើង (C20/2)

បានឃើញការតវ៉ាជំទាស់របស់ក្រុមមេធាវីការពារក្ដីរបស់ជនត្រូវចោទ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ (C20/3)។

## ការរំលឹកឡើងវិញអំពីនីតិវិធី

១. នាថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញាបានចេញនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលក្នុងនោះសហព្រះរាជអាជ្ញាបានបង្ហាញឈ្មោះ អៀង ធីរិទ្ធ ក្នុងចំណោមជនសង្ស័យចំនួនប្រាំនាក់ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ដែលឋិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ[1]។

២. នាថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់លោកស្រី អៀង ធីរិទ្ធ អំពីការដាក់លោកស្រីឲ្យឋិតនៅក្រោមការពិនិត្យចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

[1] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ (D3)។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

(ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត)[2]។

៣. នាថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ បន្ទាប់ពីមានការជជែកតទល់ សហចៅក្រមស៊ើបអង្កេតបានសម្រេចឲ្យមានការឃុំខ្លួនបណ្ដោះអាសន្ន អៀង ធីរិទ្ធ ក្នុងថេរៈវេលាអតិបរមាចំនួនមួយឆ្នាំ[3]។

៤. នាថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ សហមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ បានធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន (“បណ្ដឹងឧទ្ធរណ៍”)[4]។

៥. នាថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៨[5] បន្ទាប់ពីសវនាការ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៨ ចៅក្រមនៃអង្គបុរេជំនុំជម្រះបានយល់ស្របជាឯកច្ឆ័ន្ទលើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ហើយដែលសំអាងហេតុ ដែលមានក្នុងដីការបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានជំនួសដោយសំអាងហេតុ ដែលមានក្នុងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ។

៦. នាថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទនិងមេធាវីរបស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតគ្រោងនឹងធ្វើការបន្តថេរៈវេលានៃការឃុំខ្លួន លោកស្រី អៀង ធីរិទ្ធ ហើយថាពួកគេមានថេរៈវេលា ១៥ ថ្ងៃ ដើម្បីធ្វើការកត់សម្គាល់ និងតវ៉ា[6]។

៧. នាថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ សហមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ បានដាក់នូវការកត់សម្គាល់របស់ខ្លួន[7] ដោយទាមទារឲ្យសហចៅក្រមស៊ើបអង្កេតសម្រេចដោះលែងកូនក្ដីរបស់ខ្លួនឲ្យ

---

[2] កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ១២ វិច្ឆិកា ឆ្នាំ ២០០៨ (D39)។

[3] ដីកាសម្រេចឲ្យមានការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ (C20)។

[4] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ (C20/I)។

[5] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៨ (C20/I/26)។

[6] ការជូនដំណឹង (វិធាន ៦៣.៧) ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០០៨ (C20/2)។

មានសេរីភាព ទៅតាមលក្ខខណ្ឌ ដែលកំណត់នៅក្នុងឧបសម្ព័ន្ធ C នៃសារណាបណ្តឹងឧទ្ធរណ៍[8] ដែលរួមមាន៖

- ស្នាក់នៅ និងសម្រាករាល់យប់នៅលំនៅដ្ឋានរបស់កូនស្រីជនត្រូវចោទ ដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញ
- ស្នាក់នៅក្នុងទីក្រុងភ្នំពេញរហូត តែបើជនត្រូវចោទចង់ផ្លាស់ប្តូរទៅកន្លែងផ្សេង ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធររបស់ អ.វ.ត.ក.
- រាល់ឯកសារនៃការធ្វើដំណើរទាំងអស់ត្រូវប្រគល់ឲ្យអាជ្ញាធរ អ.វ.ត.ក. ហើយជនត្រូវចោទត្រូវសន្យាថានឹងមិនធ្វើសំណើសុំឯកសារធ្វើដំណើរថ្មីទេ
- ត្រូវគោរពបំរាមគោចរ ពីម៉ោងប្រាំបីល្ងាច ដល់ម៉ោងប្រាំពីរព្រឹក
- ត្រូវទៅបង្ហាញខ្លួនរាល់ថ្ងៃនៅទីស្នាក់ការប៉ូលីសមូលដ្ឋាន
- ហាមមានការទាក់ទងទាំងផ្ទាល់ និងមិនផ្ទាល់ជាមួយសាក្សី ជនរងគ្រោះ និងជនដែលអាចនឹងក្លាយជាសាក្សី និងមនុស្សផ្សេងទៀតដែលត្រូវហាមឃាត់
- ត្រូវបង្ហាញខ្លួននៅគ្រប់ដំណើរការនៃនីតិវិធី អ.វ.ត.ក.

## ការរំលឹកឡើងវិញអំពីច្បាប់ដែលត្រូវអនុវត្ត

៨. វិធាន ៦៣.៦.ក. នៃវិធានផ្ទៃក្នុង ចែងថា "ចំពោះ (...) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (...) សហចៅក្រមស៊ើបអង្កេតអាចពន្យាពេលការឃុំខ្លួនបណ្តោះអាសន្នបន្ថែមម្តងបាន ០១ ឆ្នាំ"។

៩. វិធាន ៦៣.៧ នៃវិធានផ្ទៃក្នុង បញ្ជាក់ថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការបន្តការឃុំខ្លួន ត្រូវធ្វើជាលាយល័ក្ខអក្សរ ហើយត្រូវមានសំអាងហេតុ។

---

[7] ការកត់សម្គាល់របស់ក្រុមមេធាវីការពារក្តី ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ ទាក់ទងនឹងលទ្ធភាពនៃការបន្តឃុំខ្លួន អៀង ធីរិទ្ធ (C20/3)។

[8] លក្ខខណ្ឌ ដែលកំណត់នៅក្នុងឧបសម្ព័ន្ធ C នៃសារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដាក់នៅថ្ងៃទី ០២ ខែមករា ឆ្នាំ ២០០៨ (C20/I/3)។

១០.	វិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង ចែងថា "សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ បានតែក្នុងលក្ខខណ្ឌដូចខាងក្រោម៖

ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ និង

ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី៖

i. រារាំងកុំឲ្យជនត្រូវចោទគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ
ii. ថែរក្សាភស្តុតាង ឬការពារមិនឲ្យបំផ្លាញភស្តុតាង
iii. ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី
iv. ការពារសន្តិសុខឲ្យជនត្រូវចោទ ឬ
v. រក្សាសណ្តាប់ធ្នាប់សាធារណៈ។

## ការរំលឹកឡើងវិញអំពីការកត់សម្គាល់របស់ក្រុមមេធាវីការពារក្តី

១១. នៅក្នុងការកត់សម្គាល់របស់ខ្លួន[9] សហមេធាវីរបស់ជនត្រូវចោទបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត មិនឲ្យធ្វើការបន្តការឃុំខ្លួន អៀង ធីរិទ្ធ និង សុំឲ្យមានការដោះលែង ក្រោមហេតុផលដូចខាងក្រោម៖

១. ក្នុងករណីនេះ លក្ខខណ្ឌនៃការបន្តការឃុំខ្លួនមិនត្រូវបានបំពេញនោះទេ៖

ក) វិធាន ៦៣ នៃវិធានផ្ទៃក្នុងមិនបញ្ជាក់អំពីលក្ខខណ្ឌនៃការបន្តការឃុំខ្លួន លើសពីថេរៈវេលាដំបូងចំនួនមួយឆ្នាំនោះ

ខ) យោងតាមយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស កាលណាថេរៈវេលានៃការឃុំខ្លួនមានរយៈពេលលើសពីមួយឆ្នាំហើយនោះ ភស្តុតាងពីអត្ថិភាពនៃហេតុផលសមរម្យ ដែលនាំឲ្យសង្ស័យថា ជនដែលត្រូវបានចាប់ខ្លួនបានប្រព្រឹត្តបទល្មើស លែងមានលក្ខណៈគ្រប់គ្រាន់ទៀតហើយ និងថាបមាណីត្រូវតែពិនិត្យឡើងវិញ

គ) ក្នុងរយៈពេលមួយឆ្នាំមកនេះ កិច្ចស៊ើបសួរមិនត្រូវបានធ្វើដោយយកចិត្តទុកដាក់នោះទេ ដូចគ្នានេះដែរ មិនមានភស្តុតាងថ្មីណា ដែលបញ្ជាក់ថា វាមានហេតុផលសមរម្យ ដែលនាំឲ្យជឿជាក់ថា ជនត្រូវចោទបានប្រព្រឹត្តបទឧក្រិដ្ឋ ដូចដែលចោទប្រកាន់នោះទេ។

២. បន្ទាប់ពីមានការឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលមួយឆ្នាំមក និងដោយយោងទៅលើផលវិបាកជាយថាហេតុនៃការបន្តការឃុំខ្លួន ជាពិសេសទាក់ទងនឹងលក្ខណៈសមហេតុផលនៃរយៈពេលនៃការឃុំខ្លួន អត្ថិភាពនៃហេតុផលសមសម្របដែលនាំឲ្យជឿបានថា ជនត្រូវចោទ បានប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចដែលត្រូវបានចោទប្រកាន់នោះ មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីជាសំអាងនៃការបន្តការឃុំខ្លួននោះទេ។

---

[9] ការកត់សម្គាល់របស់ក្រុមមេធាវីការពារក្តី ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ ទាក់ទងនឹងលទ្ធភាពនៃការបន្តការឃុំខ្លួន អៀង ធីរិទ្ធ (C20/3) កថាខណ្ឌ ១០ ១៣ និង ៣៤។

## ហេតុផលនៃសេចក្តីសម្រេច

១២. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការបន្តការឃុំខ្លួនបណ្តោះអាសន្ន ដែលលើសពីថេរៈវេលាមួយឆ្នាំ អាចធ្វើទៅបានប្រសិនបើលក្ខខណ្ឌ ដែលមានកំណត់ក្នុងវិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង នៅតែត្រូវបានបំពេញ។ លក្ខខណ្ឌទាំងនេះត្រូវតែឋិតនៅរហូត ជាមួយនិងដំណើរនៃពេលវេលា និងដំណើរការទៅមុខនៃកិច្ចស៊ើបសួរ។

### វិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង

១៣. វិធាន ៦៣.៣.ក. នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេតត្រូវបង្ហាញពីហេតុផលដែលនាំឲ្យជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

១៤. នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតគិតថាវាពិតជាមានហេតុផល ដែលនាំឲ្យជឿជាក់ច្បាស់ថា លោកស្រី អៀង ធីរិទ្ធ ធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលខ្លួនគាត់ត្រូវបានដាក់ឲ្យឋិតក្រោមការពិនិត្យ[10]។

១៥. នៅក្នុងបណ្តឹងឧទ្ធរណ៍នៃដីកានេះ និងបន្ទាប់ពីការវិភាគយ៉ាងល្អិតល្អន់នៃភស្តុតាង ដែលមាននៅក្នុងសំណុំរឿង នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៨ ដែលជាថ្ងៃសវនាការ[11] អង្គបុរេជំនុំជម្រះបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៨ ថា *"សំណុំរឿងមាន*

---

[10] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី ១៤ វិច្ឆិកា ឆ្នាំ ២០០៧ (C20) កថាខណ្ឌ ៥។

[11] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៨ (C20/I/26) កថាខណ្ឌ ៦ និង ២០។

*ភស្តុតាង ដែលអាចឲ្យអ្នកសង្កេតការសត្យានុម័តជឿថា ត្រឹមដំណាក់កាលនៃកិច្ចស៊ើបសួរនេះ ជនត្រូវចោទធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលគាត់ត្រូវបានដាក់ឲ្យនៅក្រោមការពិនិត្យ*[12]"។

១៦. ចាប់តាំងពីថ្ងៃនោះមក កិច្ចស៊ើបសួរមិនទាន់បានបញ្ចប់ទេ។ លើសពីនេះទៀត នៅក្នុងសំណុំរឿង មិនទាន់មានភស្តុតាងថ្មីណា ដែលផ្ទុយទៅនឹងភស្តុតាង ដែលអង្គបុរេជំនុំជម្រះយកមកធ្វើជាមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួននៅឡើយទេ ជាហេតុធ្វើឲ្យសំអាងហេតុរបស់អង្គបុរេជំនុំជម្រះនៅតែមានសុពលភាព។

១៧. ជាងនេះទៅទៀត ដោយផ្ទុយទៅនឹងអ្វីដែលបានលើកឡើងដោយសហមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ[13] សហចៅក្រមស៊ើបអង្កេតបានប្រមូលនូវភស្តុតាងថ្មីៗបន្ថែម ទាំងដោយខ្លួនឯង និងដោយមានការស្នើសុំពីភាគី ចាប់តាំងពីថ្ងៃទី២១ ខែ ឧសភា ឆ្នាំ ២០០៨ មកម្ល៉េះ ហើយដែលមានភស្តុតាងខ្លះៗក្នុងចំណោមភស្តុតាងទាំងនោះ បានផ្តល់នូវព័ត៌មានជាក់លាក់អំពីតួនាទីរបស់ជនត្រូវចោទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[14]។

១៨. ដោយសារហេតុផលទាំងនេះ និងបន្ទាប់ពីបានពិនិត្យជាថ្មីលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងទាំងអស់ សហចៅក្រមស៊ើបអង្កេតធ្វើសេចក្តីសន្និដ្ឋានថា នៅត្រឹមដំណាក់កាលនៃកិច្ចស៊ើបសួរនេះ ភស្តុតាងដែលប្រមូលបានទាំងអស់ អាចនឹងធ្វើឲ្យអ្នកសង្កេតការមិនលំអៀងជឿបានថា អៀង ធីរិទ្ធ ក្នុងនាមជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច បាន៖

ក) ប្រើប្រាស់អំណាច និងការគ្រប់គ្រងលើក្រសួងសង្គមកិច្ច និងស្ថាប័ននៅក្រោមចំណុះ

ខ) ជម្រុញ បញ្ជា ខកខានក្នុងការបង្ការ និងផ្តន្ទាទោស ឬជួយ និងលើកទឹកចិត្តដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មដែលខ្លួនត្រូវបានចោទប្រកាន់។

---

[12] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៨ (C20/I/26) កថាខណ្ឌ ៤១។

[13] ការកត់សម្គាល់របស់ក្រុមមេធាវីការពារក្តី ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ ទាក់ទងនឹងលទ្ធភាពនៃការបន្តការឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ (C20/3) កថាខណ្ឌ ៨-១០ និង ៣០-៣១។

[14] [លុប]


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

១៩. ជាងនេះទៅទៀត វាក៏បានបង្ហាញផងដែរថា ឧក្រិដ្ឋកម្មដែលចោទប្រកាន់លើ អៀង ធីរិទ្ធ ត្រូវបានប្រព្រឹត្តឡើងក្នុងក្របខណ្ឌនៃការវាយប្រហារ ដែលមានលក្ខណៈជាប្រព័ន្ធ និងរីករាលដាលប្រឆាំងនឹងប្រជាជនស៊ីវិល។

២០. ឆ្លងតាមការរៀបរាប់មកខាងលើនេះ យើងអាចសន្និដ្ឋានបានថា វានៅតែមានហេតុផលសមរម្យ ដែលនាំឲ្យជឿបានថា លោកស្រី អៀង ធីរិទ្ធ ធ្លាប់បានប្រព្រឹត្ត ឧក្រិដ្ឋកម្មមួយ ឬច្រើន ដែលមានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ ដូច្នេះ លក្ខខណ្ឌ ដែលមានចែងក្នុងវិធាន ៦៣.៣.ក. នៃវិធានផ្ទៃក្នុងនៅតែត្រូវបានបំពេញ។

## **វិធាន ៦៣.៣.ខ. នៃវិធានផ្ទៃក្នុង**

២១. ជាបឋម សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា សហមេធាវីរបស់លោកស្រី អៀង ធីរិទ្ធ មិនបានលើកឡើងបកស្រាយអំពីទឡ្ហីករណ៍ណាមួយទាក់ទងនឹងលក្ខខណ្ឌនៃវិធាន ៦៣.៣.ខ. នៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួនទេ។

២២. សហចៅក្រមស៊ើបអង្កេតបានរំលឹកថា ដូចដែលអង្គបុរេជំនុំជម្រះបានលើកឡើងរួចមកហើយ[15] ការសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន អាចធ្វើទៅបានប្រសិនបើលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងប្រាំ ដែលមានចែងក្នុងមាត្រា ៦៣(៣) ត្រូវបានបំពេញ ដូច្នេះសហចៅក្រមស៊ើបអង្កេតមិនចាំបាច់ត្រូវពិនិត្យលើលក្ខណៈវិនិច្ឆ័យនិមួយៗទៀតទេ ប្រសិនបើយល់ថាភាពចាំបាច់នៃការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានបញ្ជាក់រួចមកហើយតាមរយៈលក្ខខណ្ឌមួយ ឬច្រើននៃវិធាន៦៣ (៣.ខ) ។

[15] សូមមើលជាឧទាហរណ៍ C11/54 អង្គបុរេជំនុំជម្រះ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន នួន ជា ២០ មិនា ២០០៨ កថាខណ្ឌ ៨៣។

២៣. សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា នៅក្នុងសេចក្តីសម្រេចថ្ងៃ ០៩ កក្កដា ២០០៨ អង្គបុរេជំនុំជម្រះ បានធ្វើការពិនិត្យយ៉ាងល្អិតល្អន់លើលក្ខខណ្ឌនិមួយៗនៃវិធាន ៦៣.៣.ខ. នៃវិធានផ្ទៃក្នុង[16]។

២៤. ដោយយោងទៅលើសេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះ និងពិនិត្យទៅលើកាលៈទេសៈដែលកើតមាននៅថ្ងៃផុតរលត់នៃការសម្រេចការឃុំខ្លួនបណ្តោះអាសន្នលើកដំបូង សហចៅក្រមស៊ើបអង្កេតនឹងធ្វើការវិនិច្ឆ័យថាតើលក្ខខណ្ឌ ដដែលនោះនៅតែត្រូវបានបំពេញ ឬយ៉ាងណា។

វិធាន ៦៣.៣.ខ.i *"រារាំងកុំឲ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឲ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋ ដែលស្ថិតក្រោមយុត្តាធិការរបស់ អង្គជំនុំជម្រះវិសាមញ្ញ"*។

វិធាន ៦៣.៣.ខ.ii *"ថែរក្សាភស្តុតាង ឬការពារមិនឲ្យបំផ្លាញភស្តុតាង"*។

២៥. សហចៅក្រមស៊ើបអង្កេតយោងទៅដល់សំអាងហេតុដែលមាននៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ក្នុងកថាខណ្ឌលេខ ៤៣ ដល់ ៥២[17] និង សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេតរំលឹកថា វាជារឿងសំខាន់ណាស់ សម្រាប់ដំណើរការនៃកិច្ចស៊ើបសួរ ក្នុងការដែលត្រូវរារាំងការគាបសង្កត់លើសាក្សី និងជនរងគ្រោះ ដូចគ្នានិងការថែរក្សាភស្តុតាង[18]។

---

[16] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៨ (C20/I/26) កថាខណ្ឌ ៤៣ និង ៧២។

[17] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៨ (C20/I/26)។

[18] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៨ (C20/I/26) កថាខណ្ឌ ១៥។

២៦.    ទាក់ទងនឹងបញ្ហានេះ សហចៅក្រមស៊ើបអង្កេតបានគូសបញ្ជាក់ថា ជនត្រូវចោទមានសិទ្ធិចូលមើលសំណុំរឿងទាំងមូល រួមមាន៖ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និងពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ពិតមែនហើយ មុននឹងមានការចាប់ផ្តើមនីតិវិធីតុលាការ ជនសង្ស័យអាចនឹងលំបាកក្នុងការកំណត់អត្តសញ្ញាណ និងប្រើឥទ្ធិពលលើជនដែលអាចនឹងក្លាយជាសាក្សី ដែលមានចំនួនដ៏ច្រើន ប៉ុន្តែវានឹងមិនដូច្នេះទៀតទេ ប្រសិនបើជនត្រូវចោទបានដឹងអំពីអត្តសញ្ញាណរបស់សាក្សីដាក់បន្ទុក និងរបស់ជនរងគ្រោះដែលនៅក្នុងនីតិវិធី។ វាជាក់ច្បាស់ហើយដែលថា ជនត្រូវចោទបានដឹងអំពីសក្ខីកម្ម សំខាន់ៗមួយចំនួន ដែលអាចបញ្ជាក់អំពីតួនាទីរបស់គាត់នៅក្នុងរបបនោះ។ វាមានហានិភ័យមួយដែលជាក់ច្បាស់ គឺថាសាក្សីទាំងនេះនឹងមិនធ្វើការសហការណ៍ឲ្យបានស៊ីជម្រៅទៅក្នុងដំណើរការនៃនីតិវិធីទេ ប្រសិនបើ អៀង ធីរិទ្ធ ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ។ លើសពីនេះទៀត សាក្សីខ្លះៗទៀតក្នុងចំណោមសាក្សីទាំងនេះអាចនឹងត្រូវបានស្តាប់ចម្លើយឡើងវិញ ហើយពួកគេក៏បានបង្ហាញផងដែរអំពីតំរុយផ្សេងទៀត និងឈ្មោះរបស់ជនដែលអាចនឹងក្លាយជាសាក្សីផ្សេងៗទៀត ដែលមិនទាន់បានស្តាប់ចម្លើយនៅឡើយ។ វាមានហេតុផលដែលអាចនាំឲ្យជឿជាក់បានថា សាក្សីអាចនឹងទទួលរងការគាបសង្កត់ ព្រោះទីមួយ អាចបណ្តាលមកពីហេតុដែលថា ពួកគេធ្លាប់ជាអ្នកនៅក្រោមបង្គាប់របស់ជនត្រូវចោទ និងទីពីរមាន លក្ខណៈទូទៅជាងដោយសារមុខតំណែងរបស់ជនត្រូវចោទ។ ហានិភ័យនេះវាពិតជាក់ស្តែង ហើយដែលត្រូវបានបញ្ជាក់គាំទ្រដោយឥរិយាបទ និងសម្តីជាសាធារណៈរបស់ជនត្រូវចោទ[19]។

២៧.  ដូច្នេះវាពិតជាមានហានិភ័យនៃការគាបសង្កត់លើសាក្សីពិតប្រាកដមែន ដែលតម្រូវឲ្យបង្ការហានិភ័យទាំងនោះ ដើម្បីធានាភាពរលូននៃដំណើរការនៃកិច្ចស៊ើបសួរ។ ពេលវេលាដែលកន្លងផុតទៅរាប់ចាប់តាំងពីការសម្រេចដាក់ឲ្យជាប់ឃុំបណ្តោះអាសន្ន មិនបានធ្វើឲ្យបាត់ហានិភ័យទាំងអស់នេះទេ ផ្ទុយទៅវិញវារឹតតែធ្វើឲ្យខ្លាំងឡើងៗ។

---

[19] សូមមើលជាឧទាហរណ៍ សំបុត្រដែលផ្ញើដោយ អៀង ធីរិទ្ធ នៅថ្ងៃទី០៧ មករា ១៩៩៩ ទៅកាន់លោក Chris Decherd និពន្ធនាយកនៃសារព័ត៌មាន Cambodia Daily ដែលត្រូវបានបោះពុម្ពក្រោមចំណងជើងថា *"អៀងធីរិទ្ធ ថ្លែងថា គាត់គ្រាន់តែចង់បម្រើប្រជាជនគាត់ប៉ុណ្ណោះ"* កាសែតនោះចេញនៅថ្ងៃទី ១២ កុម្ភៈ ១៩៩៩ 00000588-00000589។ និងអត្ថបទ "Khmer Rouge Inc: Former Communist Embrace the Market Economy in Malai District" ថេត សម្បត្តិ និង Erika Kinetz, The Cambodia Daily ចុះថ្ងៃទី ១៧ កុម្ភៈ ២០០៧ 00106073-00106078 ដកស្រង់ដោយអង្គបុរេជំនុំជម្រះ នៅក្នុងកថាខណ្ឌ ៤៩ ដល់ ៥០ នៃសេចក្តីសម្រេច ចុះថ្ងៃទី ០៩ កក្កដា ឆ្នាំ ២០០៨។

*វិធាន ៦៣.៣.ខ.iii. "ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី"។*

២៨. នៅក្នុងដីកាចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការដាក់ឲ្យនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការមួយចាំបាច់ ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។ ជាក់ស្ដែង មានកត្តាជាច្រើនដែលបានបង្ហាញថា អៀង ធីរិទ្ធ មានមធ្យោបាយផ្នែកសំភារៈគ្រប់គ្រាន់ ក្នុងការរត់គេចខ្លួន រួមបញ្ចូលទាំងការត់គេចខ្លួនទៅកាន់ប្រទេសផ្សេងៗផង ជាពិសេសបណ្ដាប្រទេស ដែលមិនមានកិច្ចព្រមព្រៀងបត្យាប័នជាមួយកម្ពុជា។ ដូច្នេះ វាជាការបារម្ភ ដែលថាជនត្រូវចោទអាចនឹងមានបំណងរត់គេចខ្លួនពីតុលាការ ដោយគាត់អាចនឹងត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋកម្ម ដែលមានចរិតធ្ងន់ធ្ងរ។

២៩. អង្គបុរេជំនុំជម្រះបានគាំទ្រការវិភាគក្នុងលក្ខណៈនេះ នៅក្នុងកថាខណ្ឌ ៥៣ ដល់ ៥៩ នៃសេចក្ដីសម្រេចចុះថ្ងៃទី ០៩ កក្កដា ឆ្នាំ ២០០៨[20]។ រហូតមកដល់ពេលនេះ មិនទាន់មានភស្ដុតាងថ្មីណាត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ដែលអាចនាំឲ្យគិតបានថា មានកាផ្លាស់ប្ដូរកាលៈទេសៈនោះទេ។

វិធាន ៦៣.៣.ខ.v. *"រក្សាសណ្ដាប់ធ្នាប់សាធារណៈ"*

៣០. សហចៅក្រមស៊ើបអង្កេតយោងទៅដល់សំអាងហេតុនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧ ក្នុងកថាខណ្ឌ ៦៤ ដល់ ៧២ នៃអង្គបុរេជំនុំជម្រះ[21]។

[20] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០០៨ (C20/I/26)។

[21] សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០០៨ (C20/I/26)។

៣១. ដូចការបកស្រាយរបស់អង្គបុរេជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត យល់ឃើញថា លក្ខខណ្ឌនៃការថែរក្សារសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានបំពេញ ប្រសិនបើមានអង្គហេតុដែលចរិតបង្ហាញឲ្យឃើញថា ការដោះលែងឲ្យមានសេរីភាព នឹងបង្កការប៉ះពាល់យ៉ាងពិតប្រាកដដល់សណ្តាប់ធ្នាប់សាធារណៈ[22]។ សហចៅក្រមស៊ើបអង្កេត រំលឹកថា ការឃុំខ្លួននៅតែមានលក្ខណៈស្របច្បាប់ ប្រសិនបើសណ្តាប់ធ្នាប់សាធារណៈ នៅតែត្រូវបានគម្រាមកំហែងយ៉ាងពិតប្រាកដ[23]។

៣២. ចំពោះករណីនេះ វាទំនងថា ៣០ ឆ្នាំក្រោយនៃអង្គហេតុ ផលប៉ះពាល់នៃរបបខ្មែរក្រហមមកលើសង្គមកម្ពុជា នៅតែមិនទាន់បានរលាយបាត់នៅឡើយ ហើយមួយផ្នែកនៃសង្គមកម្ពុជាទទួលរងនូវរបួសផ្លូវចិត្តបន្ទាប់ពីការបញ្ចប់នៃរបប[24]។ ការយកចិត្តទុកដាក់ពីសំណាក់ប្រជាជន និងសារព័ត៌មានកម្ពុជា ចំពោះអង្គជំនុំជម្រះ និងនីតិវិធីកំពុងដំណើការ បង្ហាញឲ្យឃើញថា បញ្ហានេះនៅតែបញ្ហាកង្វល់ធំមួយសម្រាប់ប្រជាជនកម្ពុជា។ សហចៅក្រមស៊ើបអង្កេត ទទួលស្គាល់ថា ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលជនមានសម្រាប់ជនត្រូវចោទ មិនមែនជាឧបសគ្គដាច់ខាតក្នុងការដោះលែងជនត្រូវចោទឲ្យមានសេរីភាពទេ។ ប៉ុន្តែ វាជាកត្តាមួយសម្រាប់យកមកធ្វើការពិចារណាក្នុងការពិនិត្យពីលក្ខខណ្ឌដើម្បីសម្រេចពីការរក្សាការឃុំខ្លួនបណ្តោះអាសន្ន និងពីលក្ខណៈសមស្របនៃវិធានការនេះ។

៣៣. ឆ្លងតាមរយៈការបកស្រាយខាងលើ សហចៅក្រមស៊ើបអង្កេត យល់ឃើញថា បើគិតពីភាពធ្ងន់ធ្ងរនៃអង្គហេតុដែលចោទប្រកាន់ទៅលើជនត្រូវចោទ វាមិនហួសហេតុទេដែលធ្វើការសន្និដ្ឋានថា សេចក្តីសម្រេចដោះលែងឲ្យមានសេរីភាពមួយ ក្នុងបរិបទសង្គមកម្ពុជាបច្ចុប្បន្នដែលនៅផុយស្រួយ

---

[22] ពាក្យពេចន៍ "អង្គហេតុដែលមានចរិតលក្ខណៈបង្ហាញឲ្យឃើញ" រួមមានជាចាំបាច់នូវការគិតទុកជាមុនជាពិសេសក្នុងបរិបទនៃបទឧក្រិដ្ឋដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អ.វ.ត.ក។ ជាឧទាហរណ៍ សូមអានសេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍នៃដីកាសម្រេចឃុំខ្លួន អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ (C22/I/73), កថា. ១១២។

[23] សេចក្តីសម្រេចពីបណ្តឹងឧទ្ធរណ៍នៃដីកាសម្រេចឃុំខ្លួន នួន ជា បណ្តោះអាសន្ន ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៨ (C11/54), កថា. ៧៦។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នៃដីកាសម្រេចឃុំខ្លួន អៀង ធីរិទ្ធ បណ្តោះអាសន្ន ចុះថ្ងៃទី ៩ ខែកក្កដា ឆ្នាំ ២០០៨ (C20/I/27), កថា. ៦៤។

[24] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នៃដីកាសម្រេចឃុំខ្លួន អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ (C22/I/73), កថា. ១១៣។

នៅឡើយ នឹងបង្កជាហានិភ័យ ដែលនាំឲ្យមានការសំដែងការមិនពេញចិត្ត និងអាចឈានទៅដល់អំពើហិង្សា។

៣៤. ជារួមមក សហចៅក្រមស៊ើបអង្កេត វាយតម្លៃឃើញថា វានៅតែមានហានិភ័យពិតប្រាកដមួយដែលថា ជនត្រូវចោទធ្វើការគាបសង្កត់លើជនរងគ្រោះ និងសាក្សី និងយល់ឃើញថា ការរក្សាការឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បីថែរក្សាភស្តុតាង និងជៀសវាងការបំផ្លាញភស្តុតាង ព្រមទាំងដើម្បីធានាការរក្សាទុកជនត្រូវចោទសម្រាប់ដំណើរការតុលាការ និងរក្សាសណ្ដាប់ធ្នាប់សាធារណៈ អាស្រ័យហេតុនេះ លក្ខខណ្ឌនៃវិធាន ៦៣.៣.ខ. នៅតែត្រូវបានបំពេញ។

**អំពីលក្ខណៈសមហេតុផលនៃរយៈពេលនៃការឃុំខ្លួន**

៣៥. សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា ពេលវេលាដែលកន្លងផុតទៅ គឺជាធាតុមួយសម្រាប់យកមកធ្វើការពិចារណា ដើម្បីសម្រេចពីលក្ខណៈសមស្របនៃការរក្សាការឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ។ ពេលវេលានៃការឃុំខ្លួនបណ្ដោះអាសន្នដែលកន្លងផុតទៅ មិនត្រូវបានចាត់ទុកថាមិនត្រឹមត្រូវទេ ប្រសិនបើមានភស្តុតាងបង្ហាញថា នីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់។ ដើម្បីវាយតម្លៃពីរបៀបនៃការដឹកនាំនៃកិច្ចស៊ើបសួរនេះ និងដោយប្រៀបធៀបទៅនឹងយុត្តិសាស្ត្ររបស់តុលាការអ៊ឺរ៉ុបសម្រាប់សិទ្ធិមនុស្ស លើបញ្ហារយៈពេលសមស្រប សហចៅក្រមស៊ើបអង្កេតយល់ឃើញថា វាជាការចាំបាច់ដែលត្រូវគិតដល់អង្គហេតុទាំងមូល និងជាពិសេសអំពីភាពស្មុគ្រស្មាញខាងអង្គហេតុ និងអង្គច្បាប់នៃរឿងក្ដី ឥរិយាបថរបស់ភាគី និងការប្រព្រឹត្តរបស់អាជ្ញាធរតុលាការ [25]។

---

[25] CEDH, ដីកា *Frydlender ទល់នឹង France* ចុះថ្ងៃទី ២៧ មិថុនា ២០០០, លេខ ៤៣; CEDH ដីកា *Pelissier និង Sassi ទល់នឹង France* ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ១៩៩៩ , លេខ ៧១; CEDH ដីកា *Vernillo ទល់នឹង France* ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ១៩៩១, លេខ ៣៤។

៣៦. នៅក្នុងរឿងនេះ ជនត្រូវចោទត្រូវបានជាប់ឃុំអស់រយៈពេលប្រមាណជាជិត ១២ ខែមកហើយ។ រយៈពេលនេះ មិនមានលក្ខណៈហួសហេតុទេ បើគិតពីទំហំធំនៃកិច្ចស៊ើបសួរ ភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបញ្ជូនមកសហចៅក្រមស៊ើបអង្កេត[26]។

៣៧. សហចៅក្រមស៊ើបអង្កេតរំលឹកថា នៅពេលដែលសិទ្ធិនៅស្ងៀមរបស់ជនត្រូវចោទត្រូវបានទទួលស្គាល់ និងមិនអាចជំទាស់បាន ហើយសិទ្ធិមេធាវីរបស់ពួកគេក្នុងការមិនសហការសកម្មជាមួយអាជ្ញាធរតុលាការនៅក្នុងក្របខណ្ឌនៃកិច្ចស៊ើបសួរ ក៏មិនអាចជំទាស់បាននោះ ក៏ឥរិយាបទបែបនេះ មិនបានចូលរួមចំណែកដល់ការពន្លឿននីតិវិធីទេ។

៣៨. ចុងបញ្ចប់ សហចៅក្រមស៊ើបអង្កេតគូសបញ្ជាក់ថា ចាប់តាំងពីបើកការស៊ើបសួរមកសហចៅក្រមស៊ើបអង្កេត បានដឹកនាំការស៊ើបអង្កេតទៅលើបទឧក្រិដ្ឋទាំងនេះ បានប្រមូលភស្តុតាងជាច្រើន ទៅតាមសំណើសុំរបស់ភាគីនានា[27] ឬទៅតាមការផ្តួចផ្តើមរបស់ខ្លួនផ្ទាល់[28] ដែលមានមួយចំនួនបានផ្តល់ព័ត៌មានជាក់លាក់ អំពីតួនាទីដែលជនត្រូវចោទមាននៅក្នុងរបបនោះ។ រហូតមកដល់ថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ២០០៨ កំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ១៦១ ត្រូវបានដាក់ចូលក្នុងសំណុំរឿង ដែលក្នុងនោះមានមួយចំនួនបានផ្តល់ព័ត៌មានអំពីតួនាទីរបស់ អៀង ធីរិទ្ធ។ លើសពីនេះទៀត ដីកាចាត់ឲ្យស៊ើបសួរជំនួសជាច្រើនកំពុងត្រូវបានអនុវត្ត។

---

[26] នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ខ្លួន សហព្រះរាជអាជ្ញាបានបើកការស៊ើបអង្កេតបឋម លើបុគ្គលប្រាំរូប ចំពោះអំពើដែលបានប្រព្រឹត្ត នៅលើទឹកដីកម្ពុជាទាំងមូលក្នុងអំឡុងពេលដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ អ.វ.ត.ក និងបានស្នើបទចោទប្រកាន់បទឧក្រិដ្ឋជាតិ និងអន្តរជាតិជាច្រើន និងស្មុគស្មាញ [លុប]

[27] [លុប]

[28] [លុប]


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

៣៩. យោងតាមការបកស្រាយខាងលើ ពេលវេលាដែលកន្លងផុតទៅ មិនបានធ្វើឲ្យប៉ះពាល់ដល់ចរិតលក្ខណៈចាំបាច់នៃការរក្សាការឃុំខ្លួនបណ្តោះអាសន្ននោះទេ។

៤០. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ផ្អែកលើសំអាងច្បាប់ និងសំអាងហេតុអត្ថាធិប្បាយខាងលើ វានៅតែមានហេតុផលដែលគួរឲ្យជឿបានថា អ្នកស្រី **អៀង ធីរិទ្ធ** អាចបានប្រព្រឹត្តបទឧក្រិដ្ឋដែលចោទប្រកាន់ទៅលើរូបគាត់។ ម្យ៉ាងទៀត សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ដើម្បីជៀសវាងការគាបសង្កត់លើជនរងគ្រោះ ឬសាក្សី ព្រមទាំងដើម្បីរក្សាភស្តុតាង ឬជៀសវាងការបំផ្លាញភស្តុតាង រក្សាសណ្តាប់ធ្នាប់សាធារណៈ និងដើម្បីធានានូវអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី វាជាការចាំបាច់ដែលត្រូវបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន។

## អាស្រ័យហេតុនេះ

**សម្រេច** បន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន **អៀង ធីរិទ្ធ** ក្នុងរយៈពេលអតិបរមាចំនួនមួយឆ្នាំបន្ថែមទៀត ដោយអនុលោមតាមបទប្បញ្ញត្តិនៃវិធាន ៦៣.៦.ក). នៃវិធានផ្ទៃក្នុង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.